# របាយការណ៍
# ស្តីពី
# លទ្ធផលនៃការពិនិត្យការអនុវត្តចំណូលថវិកាប្រចាំត្រីមាសទី១ ឆ្នាំ២០២០
# ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## (I)-ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០

យោងតាមព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ បានប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០។ នៅក្នុងច្បាប់នេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានគ្រោងចំណូលឆ្នាំ២០២០ សរុបមានចំនួន ៤១ ៥២៧,៤ លានរៀល ក្នុងនោះ ៖

**(ក) រដ្ឋបាលកណ្តាល៖** បានគ្រោងចំណូលសរុបចំនួន ៤១ ៥២៦ លានរៀល ចំណូលនេះរួមមាន :

(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន ២៧ ៩២៥លានរៀល ស្មើនឹង១០៣,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ១០ ៧៥១ លានរៀល ស្មើនឹង១១៤,៣% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ (៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន២ ៨៥០ លានរៀល ស្មើនឹង១០១,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ ។

**(ខ) មន្ទីររាជធានី ខេត្ត៖** បានគ្រោងចំណូលសរុបចំនួន១,៤ លានរៀល ស្មើនឹង ០,០០៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៩ ចំណូលនេះបានគ្រោងពីការជួលដីទំនេរនៃផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវារបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។ ការគ្រោងចំណូលឆ្នាំ២០២០ មានការថយចុះ គឺដោយសារចំណូលពីសេវាសាធារណៈរបស់មន្ទីររាជធានី ខេត្តស្ទើរទាំងអស់ត្រូវបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

## (II)-លទ្ធផលសម្រេចបាន

ដោយអនុវត្តតាមច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ គិតមកត្រឹមថ្ងៃទី០២ ខែមេសា ឆ្នាំ២០២០ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តប្រមូលចំណូលសរុបមានចំនួន ១០ ៨៦៧,១ លានរៀល ស្មើនឹង ២៦,១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ក្នុងនោះ ៖

**(ក) រដ្ឋបាលកណ្តាល៖** អនុវត្តប្រមូលចំណូលសរុបមានចំនួន ១០ ៨៦៧,១ លានរៀល ស្មើនឹង ២៦,២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ចំណូលនេះរួមមាន (១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋមានចំនួន ៤ ៤៩៤,៥លានរៀល ស្មើនឹង១៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (២)ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិនិងសេវាមានចំនួន ៥ ៤០៥,៨ លានរៀល ស្មើនឹង៥០% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (៣) ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម មានចំនួន ៩២០,៩ លានរៀល ស្មើនឹង៣២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ។

**(ខ) មន្ទីររាជធានី ខេត្ត ៖**

មិនទាន់មានការបង់ចំណូលពីថ្លៃឈ្នួលដី សម្រាប់ត្រីមាសទី១នេះ។

ជារួមការអនុវត្តចំណូលរបស់រដ្ឋបាលកណ្តាលស្ថិតនៅក្នុងកម្រិតស្តង់ដារជាមធ្យម ប៉ុន្តែបើពិនិត្យទៅតាមប្រភេទចំណូលនីមួយៗឃើញថាការអនុវត្តប្រមូលចំណូលនេះមានភាពកើនខ្ពស់ និងចុះទាប ឬមិនអាចប្រមូលបាន ជាក់ស្តែងដូចជា(១)ផលទុននៃទ្រព្យសម្បត្តិរដ្ឋអនុវត្តបានតែ១៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ករណីនេះបណ្តាលមកពីចំណូលពីផលនេសាទមិនអាចប្រមូលបាន ដោយសារមិនទាន់មានការណែនាំច្បាស់លាស់អំពីនីតិវិធីនៃការបង់ចំណូលចាប់តាំងពី

ចំណូលនេះត្រូវបានផ្ទេរទៅថ្នាក់ក្រោមជាតិ ។ ទន្ទឹមនឹងនេះចំណូលពីសម្បទានដីសេដ្ឋកិច្ចអនុវត្តបានល្អគឺ៣១% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ រីឯចំណូលផលពីព្រៃឈើអនុវត្តបាន១២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (២)ផលទុនពីការជួលទ្រព្យសម្បត្តិនិងសេវាអនុវត្តបានខ្ពស់នៅដើមឆ្នាំគឺ ៥០%ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ លទ្ធផលនេះគឺដោយសារចំណូលពីការជួលដីទំនេរអនុវត្តបាន ៣៣%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០និងការជួលដីមានអគារអនុវត្តបាន២៣% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ។ ដោយឡែកចំណូលពីការគ្រប់គ្រងរដ្ឋបាលអនុវត្តបានខ្ពស់ ដូចជាការត្រួតពិនិត្យអនាម័យសត្វអនុវត្តបាន៧២% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០និងផលពីការត្រួតពិនិត្យគុណភាពផលិតផលនិងការគោរពបទដ្ឋានអនុវត្តបាន ៥២% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ (៣)ចំណូលពីការផាកពិន័យនិងដាក់ទណ្ឌកម្មអនុវត្តបាន៣២% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ លទ្ធផលនេះបានមកដោយសារការផាកពិន័យលើផលិតផលសាច់សត្វ និងការដឹកជញ្ជូនសត្វរបស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ អនុវត្តបាន ៧០០% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ការពិន័យលើការទិញ-លក់ជីនិងថ្នាំកសិកម្មខុសច្បាប់ អនុវត្តបាន៥៣% នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ការពិន័យលើការនេសាទខុសច្បាប់ អនុវត្តបាន៤៤%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ និងការពិន័យលើបទល្មើសព្រៃឈើ អនុវត្តបាន ៣៣%នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២០ ។

(III)-**ទិសដៅអនុវត្តបន្ត**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្តខិតខំនិងជំរុញការប្រមូលចំណូលបង់ចូលថវិកាជាតិស្របទៅតាមកម្មវិធីចំណូលប្រចាំត្រីមាសទី២ ដែលមានទឹកប្រាក់សរុបចំនួន ១៣ ៥៨៤ ៨០០ ០០០រៀល។ កិច្ចការបន្ទាន់មួយទៀតដែលក្រសួងត្រូវអនុវត្ត ដើម្បីរួមចំណែកក្នុងការប្រមូលចំណូលទៅតាមផែនការគឺត្រៀមរៀបចំកិច្ចប្រជុំពិភាក្សាពីការបង់ចំណូលពីផលនេសាទចូលថវិការដ្ឋទៅតាមពេលវេលាមួយសមស្រប ។

(IV)-**សេចក្តីសន្និដ្ឋាន**

ទោះបីជារួមការការអនុវត្តប្រមូលចំណូលប្រចាំត្រីមាសទី១ ទទួលបានលទ្ធផលក្នុងកម្រិតស្តង់ដារហើយក្តីក៏នៅមានចំណូលផ្សេងៗទៀតដែលមិនទាន់បានអនុវត្តដូចជា ចំណូលពីការលក់ផលិតផលកសិកម្ម ការលក់សម្ភារបរិក្ខារ សម្ភារខូចខាតនិងចំណូលពីផលនេសាទ។

ដូច្នេះដើម្បីកែលម្អការប្រមូលចំណូលឲ្យបានតាមផែនការ អង្គភាពពាក់ព័ន្ធទទួលបន្ទុកប្រមូលចំណូលត្រូវបង្កើនការយកចិត្តទុកដាក់និងរួសរាន់ធ្វើការបង់ចំណូលដែលទទួលបានចូលថវិកាជាតិ។

ថ្ងៃ ព្រហស្បតិ៍ ៨រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមេសា ឆ្នាំ២០២០

**រដ្ឋលេខាធិការ**

**និងជាប្រធានក្រុមការងាររៀបចំថវិកា**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**យុទ្ធ ភូថង**